**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ ២៧៤.០៥.១៣ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៣

**ជម្រាបមក**

**លោកអភិបាលក្រុង ស្រុកគោលដៅ នៃគម្រោងការិយាល័យច្រកចេញចូលតែមួយ**

**កម្មវត្ថុ** ៖ ស្តីពីការបើកប្រាក់ចំណាយប្រតិបត្តិការអាទិភាពជូនមន្ត្រីរាជការ ដែលបានជ្រើសរើសចូលបំពេញការងារក្នុងគម្រោងការិយាល័យច្រកចេញចូលតែមួយនៅតាមបណ្តាក្រុង ស្រុកគោលដៅ។

**យោង** ៖ លិខិតលេខ ០២០សណន/គ.ជ.អ.ប ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការបិទគម្រោង និងគណនីបំពេញចំណាយរបស់គម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកថា ផ្អែកតាមខ្លឹមសារនៃលិខិតដូចមានចុះក្នុងយោងខាងលើ គម្រោងការិយាល័យច្រកចេញចូលតែមួយនឹងធ្វើការបិទគណនីបំពេញចំណាយរបស់គម្រោងនៅតាមបណ្តាខេត្តគោលដៅទាំងអស់នៅចុងខែមីនា ឆ្នាំ២០១៣នេះ។ ជាមួយនេះ ការគាំទ្រលើប្រាក់ចំណាយប្រតិបត្តិការអាទិភាពពីធនាគារពិភពលោកក៏នឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣នេះ ផងដែរ។

ទាក់ទិននឹងបញ្ហានេះ ដើម្បីធានាដល់ការទូទាត់ប្រាក់ចំណាយប្រតិបត្តិការអាទិភាពចំពោះមន្ត្រី ដែលបានជ្រើសរើសឲ្យមកបំពេញការងារនៅក្នុងគម្រោងការិយាល័យច្រកចេញចូលតែមួយរួចហើយ ប៉ុន្តែមិនទាន់មានប្រកាសតែងតាំងជាផ្លូវការពីក្រសួងមហាផ្ទៃនៅឡើយនោះ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការបើកប្រាក់រំលឹកចំណាយប្រតិបត្តិការអាទិភាពជូនមន្ត្រីទាំងនោះ ចេញពីគណនីថ្នាក់ជាតិដោយផ្ទាល់។

អាស្រ័យហេតុនេះ សូមលោកអភិបាលក្រុង ស្រុកគោលដៅនៃគម្រោងការិយាល័យច្រកចេញចូលតែមួយទាំងអស់ ស្នើឲ្យមន្ត្រីដែលមានឈ្មោះក្នុងបញ្ជីភ្ជាប់មកជាមួយ បើកគណនីផ្ទាល់ខ្លួនជាប្រាក់រៀលនៅធនាគារអេស៊ីលីដា និងបញ្ជូនមកក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ **ឲ្យបានមុនថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣**។

សូមលោកអភិបាលទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អនុប្រធានប្រតិបត្តិ នៃលេខាធិការដ្ឋានគ.ជ.អ.ប**

**ឪវ៉ាន់ ចំរើន**